គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ភ្នំពេញ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣

# របាយការណ៍បឋម
# ស្តីពី
# ការអង្កេតស្រាវជ្រាវសំរាប់ការបោះឆ្នោត និងសវនកម្មបញ្ជីបោះឆ្នោតឆ្នាំ២០១២ សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០១៣

គណៈកម្មាធិការខុមហ្វ្រែល បាននិងកំពុងធ្វើការអង្កេតស្រាវជ្រាវ និងការធ្វើសវនកម្មបញ្ជីបោះឆ្នោតឆ្នាំ២០១២ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៥ ឆ្នាំ ២០១៣ខាងមុខនេះ ។

ការអង្កេតស្រាវជ្រាវ និងការធ្វើសវនកម្មនេះតាមវិទ្យាសាស្ត្របានចាប់ដោយចៃដន្យ សំណាកនៃអ្នកមានសិទ្ធិបោះឆ្នោតចំនួន ២,៦០០នាក់ នៅ២២៥ការិយាល័យទូទាំងប្រទេសដើម្បីសម្ភាសន៍ទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ហើយទិន្នន័យអ្នកមានឈ្មោះបោះឆ្នោត ទិន្នន័យរបស់អ្នកសម្ភាសន៍បានត្រូវយកមកផ្ទៀងផ្ទាត់ជាមួយទិន្នន័យបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១២ ដំបូង និងផ្លូវការ ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១២ ជាពិសេសអត្តសញ្ញាណរបស់អ្នកបោះឆ្នោត, សិក្សាពីអ្នកមានសិទ្ធិបោះឆ្នោត តែគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការលុបឈ្មោះអ្នកបោះឆ្នោត។

ខាងក្រោមគ្រាន់តែជារបាយការណ៍ដំបូងនៃការអង្កេតស្រាវជ្រាវនេះ ប៉ុន្តែរបាយការណ៍ចុងក្រោយនៃការអង្កេតស្រាវជ្រាវ និងសវនកម្មនេះនឹងត្រូវបានចេញយ៉ាងយូរនៅដើមខែមីនា ឆ្នាំ ២០១៣ ។

***ការអង្កេតស្រាវជ្រាវរបស់ខុមហ្វ្រែលបានរកឃើញថា៖***

- មានតែ ៩៧.៧% នៃអ្នកមានសិទ្ធិបោះឆ្នោតបានចុះឈ្មោះបោះឆ្នោត។ បើធ្វើការប្រៀបធៀបទៅនឹងលទ្ធផលនៃការសិក្សាឆ្នាំ២០១១គឺមានការកើនឡើង ៣.៥%។ សម្រាប់ឆ្នាំ២០១២នេះ គ.ជ.ប បានចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតបានចំនួន ១០១.៧៤% (៩,៦៧៥,៤០៣នាក់) នៃអ្នកមានសិទ្ធិបោះឆ្នោត(ការប៉ាន់ស្មានរបស់ខ្លួន ៩,៥០៩,៧៣២នាក់)។

រូបភាពទី ១៖ កំរិតនៃការចុះឈ្មោះបោះឆ្នោត




ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

• ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោតទាំងអស់ មានតែ ៤.៤% ជាអ្នកចុះឈ្មោះថ្មី ប៉ុន្តែយោងតាមលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត២០១២របស់គ.ជ.ប មានអ្នកចុះឈ្មោះថ្មីសំរាប់ឆ្នាំ ២០១២ មានប្រមាណ ៩,៧% ។

រូបភាពទី ២៖ អ្នកមានសិទ្ធិបោះឆ្នោតបានចុះឈ្មោះថ្មី




• យុវជនដែលគ្រប់អាយុ ១៨ ឆ្នាំ គិតទៅដល់ការបោះឆ្នោតឆ្នាំ ២០១៣ មានតែ ៨៦% បានចុះឈ្មោះបោះឆ្នោត មានប្រមាណ ៣១៨,២០០នាក់ បើយោងតាមរបាយការណ៍ជំរឿន ២០០៨ នៃវិទ្យាស្ថានជាតិស្ថិតិ មានចំនួនប្រមាណជាង ៣៧០,០០០នាក់ ដែលនឹងគ្រប់អាយុចុះឈ្មោះបោះឆ្នោតបើគិតទៅដល់ថ្ងៃបោះឆ្នោត ២០១៣។ តារាងលទ្ធផលផ្លូវការរបស់គ.ជ.ប មិនបានបង្ហាញពីចំនួនអ្នកចុះឈ្មោះបោះឆ្នោតថ្មីដែលទើបគ្រប់អាយុ ១៨ ឆ្នាំ បើគិតដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ និងអ្នកដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ព្រមទាំងអ្នកផ្លាស់ទីលំនៅដែលត្រូវចុះឈ្មោះថ្មី។ បើធៀបជាមួយអ្នកចុះឈ្មោះបោះឆ្នោតថ្មី ក្រុមប្រឹក្សាឃុំ សង្កាត់ និងគ.ជ.ប បានចុះឈ្មោះអ្នកបោះឆ្នោតថ្មីមានចំនួន ៩៤០,៤៤៩នាក់ លើសពីការប៉ាន់ប្រមាណ ៦១៩,៦៣០នាក់ មានន័យថា បាន ១៤៨% ដែលនាំឲ្យមានភាពមិនច្បាស់លាស់អំពីអ្នកចុះឈ្មោះបោះឆ្នោតថ្មី។

រូបភាពទី ៣៖ យុវជនអាយុ ១៨ឆ្នាំគិតដល់ថ្ងៃបោះឆ្នោត ២០១៣ បានចុះឈ្មោះបោះឆ្នោត



- លទ្ធផលចុះឈ្មោះបោះឆ្នោតផ្លូវការរបស់គ.ជ.បមានចំនួនលើស ១០១,៧៤% នៃចំនួនប៉ាន់ប្រមាណនៃអ្នកមានសិទ្ធិបោះឆ្នោតសរុប ប៉ុន្តែការអង្កេតស្រាវជ្រាវរបស់ខុមហ្វ្រែលរកឃើញថា នៅមានអ្នកអត់បានចុះឈ្មោះបោះឆ្នោតប្រហែល ២,៣% នៃអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត ដែលក្នុងនោះក្នុងចំណោមពួកគេបានពន្យល់ពីហេតុផលដែលមិនបានចុះឈ្មោះបោះឆ្នោត(រូបភាពទី ៤)ដូចជា៖
    - ២៦.១៥% មិនមានឯកសារបញ្ជាក់អត្តសញ្ញាណក្នុងការចុះឈ្មោះបោះឆ្នោត
    - ២០% ពុំបានទទួលព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត
    - ១៥.៣៨% មានជំងឺ
    - ១០.៧៧% បានផ្លាស់ទីលំនៅថ្មី និងគ្មានលិខិតបញ្ជាក់ទីលំនៅ
    - ១០.៧៧% មិនដឹងថាខ្លួនមានសិទ្ធិចុះឈ្មោះបោះឆ្នោត
    - ៩.២៣% មិនមានពេលវេលាគ្រប់គ្រាន់ទៅចុះឈ្មោះបោះឆ្នោត
    - ៩.២៣% ការចុះឈ្មោះតម្រូវឲ្យគាត់ចំណាយថវិកាច្រើន បាត់បង់ប្រាក់ចំណូល ខាតការងារ និងព្រមទាំងត្រូវចំណាយពេលវេលាយូរក្នុងការធ្វើដំណើរ
    - ៦.១៥% គិតថាខ្លួនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត
    - ៣.០៨% មិនអាចរកសាក្សីក្នុងការធ្វើលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត
    - ៣.០៨% ទីកន្លែងចុះឈ្មោះមិនបង្កលក្ខណៈងាយស្រួល
    - ៣.០៨% ធុញនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
    - ៣.០៨% មិនមានថវិកា
    - ១.៥៤% ការិយាល័យចុះឈ្មោះនៅឆ្ងាយពេក

រូបភាពទី ៤៖ មូលហេតុដែលមិនបានចុះឈ្មោះបោះឆ្នោត



• ក្នុងចំណោមអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោត ៦៧.២១% មានចំណេះដឹងត្រឹមតែកម្រិតបឋមសិក្សា ឬមិនចេះអាន និងសរសេរអក្សរ។ សម្រាប់ការសិក្សាក្នុងឆ្នាំ២០១១ គឺមានចំនួនច្រើនជាង ៧០%។ លទ្ធផលនេះបញ្ជាក់ថាកម្រិតនៃការអប់រំក៏ជាកត្តាមួយដែលមានទំនាក់ទំនងដល់ការចេញទៅចុះឈ្មោះបោះឆ្នោត ព្រោះថាអ្នកមានកម្រិតចំណេះដឹងខ្ពស់បានចេញទៅចុះឈ្មោះបោះឆ្នោតច្រើនជាង អ្នកមានមានកម្រិតចំណេះដឹងទាប។

រូបភាពទី ៥៖ អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតដែលមិនបានចុះឈ្មោះបោះឆ្នោតធៀបកំរិតអប់រំ




• ក្នុងចំណោមអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោត ៨០.៣% ជាអ្នកដែលមានមុខរបរផ្ទាល់ខ្លួន ដែលការសិក្សាក្នុងឆ្នាំ២០១១គឺមានរហូតដល់ ៩០.៩%។

• ១៣.១% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនបានធ្វើការចុះឈ្មោះបោះឆ្នោតដោយខ្លួនឯង។ មានន័យថាមានអ្នកណាម្នាក់បានជួយចាត់ចែងការចុះឈ្មោះ (អាចជាបង ប្អូន ឪពុកម្តាយ ឬអាជ្ញាធរ) ដោយមិនចាំបាច់បង្ហាញវត្តមានខ្លួននៅចំពោះមុខស្មៀន។ ការសិក្សានៅឆ្នាំ២០១១ រកឃើញតែ ២.៤%។

• ២.៦% នៃអ្នកផ្តល់បទសម្ភាសន៍បានជួបការលំបាកក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

• ប្រភពព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គឺនៅតែភាគច្រើនបានតាមរយៈមេភូមិ និងតាមរយៈទូរទស្សន៍ និងវិទ្យុ។

• ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ ៧៥.៥០% មិនស្គាល់បញ្ជីបោះឆ្នោតដំបូង។

• ៣០.១% នៃអ្នកផ្តល់បទសម្ភាសន៍មិនបានដឹងថា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផុតសុពលភាពអាចប្រើប្រាស់ក្នុងការបោះឆ្នោតឆ្នាំ២០១៣នេះបាន។

• ៦៥.៣% នៃអ្នកចុះឈ្មោះបោះឆ្នោតបានទៅធ្វើការពិនិត្យឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១២។ ក្នុងចំណោមអ្នកបានចុះឈ្មោះបោះឆ្នោត ហើយមិនបានទៅពិនិត្យឈ្មោះបានបញ្ជាក់ហេតុផលដូចខាងក្រោម៖

- ៤៩.៦% គាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ
- ២១.២% មិនបានទទួលព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ២២.៤% មិនមានពេលវេលាគ្រប់គ្រាន់
- ៩.៧% គាត់មានជំងឺ
- ៥.៩% មិនដឹងថាមានសិទ្ធិចូលរួម
- ៤.២% ធុញនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ៣.៥% ការិយាល័យចុះឈ្មោះនៅឆ្ងាយពេក
- ១.៩% ផ្លាស់ប្តូរទីលំនៅ
- ១.៩% ចំណាកស្រុក
- ១.៣% គ្មានថវិកា
- ០.៦% កន្លែងចុះឈ្មោះមិនបង្កលក្ខណៈងាយស្រួល
- ០.១% មានការប្រកាន់គណបក្សនយោបាយ

• ១.៩១% នៃអ្នកផ្តល់បទសម្ភាសន៍មិនមានឯកសារសម្គាល់អត្តសញ្ញាណសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតទេ ដែលក្នុងនោះ ២៨.៦% បានបញ្ជាក់ថា វាមិនមានសារៈសំខាន់, ៨.២% ត្រូវបានគេដកហូត, ៨.៨២% គ្មានថវិកាក្នុងការបង្កើត និង ៥៥.១% បានបញ្ជាក់ហេតុផលផ្សេងៗ។

រូបភាពទី ៦៖ មូលហេតុដែលមិនមានឯកសារ




• ៣៩.៣% នៃអ្នកផ្តល់បទសម្ភាសន៍បានផ្តល់អនុសាសន៍ឲ្យមានការផ្លាស់ប្តូរបញ្ជីបោះឆ្នោតបច្ចុប្បន្នទាំងស្រុង។ ២៥% បានផ្តល់អនុសាសន៍ឲ្យមានការកែលំអលើបញ្ជីបោះឆ្នោតបច្ចុប្បន្ន។ ដោយឡែក ៣៥.៧% ផ្សេងទៀតបានផ្តល់អនុសាសន៍ផ្សេងក្រៅពីចំណុចខាងលើ។ គួរកត់សម្គាល់ថា អ្នកមានសិទ្ធិបោះឆ្នោតបានផ្តល់អនុសាសន៍

ឲ្យមានការផ្លាស់ប្តូរបញ្ជីបោះឆ្នោតបច្ចុប្បន្នទាំងស្រុងមានកើនឡើង ២០.៩៤% បើប្រៀបធៀបនឹងការសិក្សាក្នុងឆ្នាំ២០១១។

• ១១,៥% នៃអ្នកចុះឈ្មោះបោះឆ្នោតមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

រូបភាពទី ៧៖ អ្នកមានសិទ្ធិបោះឆ្នោតមិនមានអត្តសញ្ញាណប័ណ្ណ




គ.ជ.ប គួរមានតារាងបន្ថែមស្តីពីលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតរបស់គ.ជ.ប ដើម្បីបង្ហាញពីចំនួនអ្នកចុះឈ្មោះថ្មី (អ្នកទើបគ្រប់អាយុ អ្នកផ្លាស់ទីលំនៅ និងអ្នកដែលមិនទាន់បានចុះឈ្មោះពីមុនមក) ព្រោះថា គណបក្សនយោបាយនានាបានចោទប្រកាន់អំពីការប៉ោងចំនួនអ្នកបោះឆ្នោតច្រើននៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ព្រោះមានអ្នកមិនគ្រប់អាយុបានបោះឆ្នោត។ ជាការពិតបញ្ជីនេះបន្តមានឈ្មោះខ្មោច ឬ/និងឈ្មោះស្ទួនជាច្រើន ។

ដោយសារគ.ជ.ប និងក្រុមប្រឹក្សាឃុំ សង្កាត់ខ្លះបានសហការផ្តល់បញ្ជីបោះឆ្នោតដំបូង និងផ្លូវការ បញ្ជីលុបឈ្មោះអ្នកបោះឆ្នោត ១០១៦ (ចំនួនឈ្មោះត្រូវបានលុបចេញពីបញ្ជី ៤៦៨,៤៨៥នាក់) ខុមហ្វ្រែលបន្តធ្វើសវនកម្ម និងផ្ទៀងផ្ទាត់ទិន្នន័យ និងបញ្ជីខាងលើរបស់គ.ជ.ប ដើម្បីរកឲ្យឃើញកម្រិតត្រឹមត្រូវនៃទិន្នន័យ អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ការលុបឈ្មោះ និងភាពប្រែប្រួលទិន្នន័យដែលធ្វើដោយស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយទិន្នន័យដែលបញ្ចូលទៅក្នុងបញ្ជីផ្លូវការ ។


***<u>សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:</u>***

កញ្ញា គង់ រ៉ាវីន, អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល, ០១២ ៦៥៤ ៩៥០, អ៊ីម៉ែល: ravine@comfrel.org


***<u>បេសកម្ម</u>*** *៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/* ***ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌*** *តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/* ***ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត*** *តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។*